**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៩៤៩១.....អពដ

ថ្ងៃសុក្រ ៨រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៨

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការពន្យារពេលប្រកាសបង់ប្រាក់ពន្ធតែមប្រិ៍សារពើពន្ធលើកទី២ សម្រាប់ឆ្នាំ ២០១៨

អនុលោមតាមប្រកាសលេខ ៩៨២ សហវ.ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការអនុវត្តអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន លោក/លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬម្ចាស់អាជីវកម្មដ្ឋានទាំងអស់ ដែលបានលើកស្លាកអាជីវកម្មដ្ឋាន ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម និងផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម មេត្តាជ្រាបថា ការប្រមូលពន្ធតែមប្រិ៍សារពើពន្ធត្រូវបានបញ្ចប់ត្រឹមថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា មកដល់ពេលនេះ មានម្ចាស់សហគ្រាស និងម្ចាស់អាជីវកម្មដ្ឋានជាច្រើនបានមកប្រកាសបង់ពន្ធតែមប្រិ៍សារពើពន្ធសម្រាប់ឆ្នាំ២០១៨ ហើយក៏នៅមានម្ចាស់សហគ្រាស និងម្ចាស់អាជីវកម្មដ្ឋានមួយចំនួនទៀត នៅមិនទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធតែមប្រិ៍សារពើពន្ធនៅឡើយ។ ដើម្បីផ្ដល់លទ្ធភាពជូនម្ចាស់សហគ្រាស និងម្ចាស់អាជីវកម្មដ្ឋានដែលមិនទាន់បានមកប្រកាសបង់ពន្ធតែមប្រិ៍សារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារពេលការប្រកាសបង់ពន្ធតែមប្រិ៍សារពើពន្ធលើកទី២ សម្រាប់ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣០ **ខែកញ្ញា ឆ្នាំ២០១៨**។

ចំពោះសហគ្រាស ឬអាជីវកម្មដ្ឋានស្ថិតនៅក្នុងរាជធានីភ្នំពេញ ត្រូវមកដាក់លិខិតប្រកាសបង់ប្រាក់ពន្ធតែមប្រិ៍សារពើពន្ធនៅទីចាត់ការពន្ធដាររាជធានីភ្នំពេញ ដែលមានអាសយដ្ឋាននៅអាគារលេខ ៩២ F (ក្បែរអគ្គនាយកដ្ឋានពន្ធដារ) មហាវិថីសហព័ន្ធរុស្ស៊ី (១១០) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដោយឡែក សហគ្រាស ឬអាជីវកម្មដ្ឋានដែលស្ថិតនៅតាមបណ្ដាខេត្ត ត្រូវមកដាក់លិខិតប្រកាសបង់ប្រាក់ពន្ធតែមប្រិ៍សារពើពន្ធនៅតាមបណ្ដាសាខាពន្ធដារខេត្តនីមួយៗ។ ម្ចាស់សហគ្រាសនិងម្ចាស់អាជីវកម្មដ្ឋាន ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតលើកស្លាកសញ្ញាអាជីវកម្មពីអាជ្ញាធរឬស្ថាប័នពាក់ព័ន្ធ រូបថតនិងទំហំស្លាក បង្កាន់ដៃប្រាក់ពន្ធបានបង់ឆ្នាំមុន ប័ណ្ណពន្ធប៉ាតង់ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

លោក/លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬម្ចាស់អាជីវកម្មដ្ឋាន អាចទាញយកទម្រង់លិខិតប្រកាសពន្ធតែមប្រិ៍សារពើពន្ធ តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ (www.tax.gov.kh) ឬទទួលយកនៅទីចាត់ការពន្ធដាររាជធានីភ្នំពេញ ឬសាខាពន្ធដារខេត្ត។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ការពន្យារពេលខាងលើនេះ នឹងជួយសម្រួលដល់លោក/លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬម្ចាស់អាជីវកម្មដ្ឋាន ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។ ក្នុងករណីហួសកាលកំណត់នេះ សហគ្រាស ឬអាជីវកម្មដ្ឋានរបស់លោក/លោកស្រីត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្ដីពីសារពើពន្ធ។

Collection by VCAT Professional Consultant

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh